USAID
FROM THE AMERICAN PEOPLE

# SCHOOL DROPOUT PREVENTION PILOT PROGRAM



### *Program Overview*

The School Dropout Prevention Pilot (SDPP) program is a three-year multi-country program, funded by USAID, aimed at mitigating school dropout in primary and secondary school.

The SDPP Program will:

- Design and test the effectiveness of interventions to prevent school dropout in four countries—Cambodia, India, Tajikistan, and Timor Leste.
- Generate evidence for interventions that can be used by USAID and ministries of education to decrease dropout levels and address dropout-related behaviors that put students at risk.

## Cambodia

### *Dropout Trends*

Analysis of Cambodia's Education Management Information System data shows that:

- Dropout is most acute at the lower secondary cycle among male and female students (20%), compared with primary (9%) and upper secondary cycle (12%).
- Dropout is highest in Grades 7, 8, 9.
- The dropout rate spikes in key entry/exit points for the various educational levels—grades 7 (20%), grade 9 (21%), and grade 12 (15%).




### *Dropout in Context*

A situational analysis was conducted in three high-dropout provinces to identify the factors and conditions associated with dropout, develop a profile of a child at risk of dropping out, and inform intervention selection and design. The top reasons of student dropout among 7th, 8th, and 9th grade students in the target provinces—cited by at-risk students, dropouts, and their parents/guardians— are both economic and academic.

Economic reasons are the top three reasons cited:

- Nearly three-quarters of the at-risk students, dropouts, and dropouts' parents/guardians cited the need to supplement income through household chores or domestic work. About half cited the need to work to earn money.
- 50% of at-risk students and their parents/guardians and 33% of dropouts and parents/guardians cited school-related expenses.

Students also drop out of school for academic reasons:

- About one-third of dropouts and one-fifth of at-risk students said they were unable to keep up with their lessons.
- About 20% of at-risk students and dropouts cite poor academic performance.
- Chronic absenteeism is a major contributor to dropout. Over half of at-risk students and one-third of dropouts have missed more than 15 consecutive days of school; 80–90% missed up to four days per month. 66% of at-risk parents/guardians reported they have kept their child at home when not ill; while 56% of the parents/guardians reported they were not aware of their child's school attendance.
- Negative behavior exists: About 16% of child respondents say they have broken school rules.
- Parents/guardians were twice as likely as their child to say the child did not like school.

Other factors (10% of respondents) cited for dropout were: illness and distance to school. Factors not frequently cited: poor school quality, overage, discouraged by teachers, marriage, and lack of latrines.

Top Reasons of Dropout by Students, Dropouts, Parent/Guardians




Top Reasons of Dropout by School Personnel, District Education Officer (DEO), Community Leaders




## The Interventions

In agreement with the Ministry of Education, Youth and Sport, SDPP will target grades 7, 8, and 9 in six provinces—Banteay Meanchey, Battambang, Kampong Speu, Prey Veng, Pursat, and Svay Rieng. Key education stakeholders attended a design workshop to develop ideas for dropout mitigation through a consultative process. Two priority interventions—an Early Warning System and Computer Labs—were developed, consistent with the ministry strategic sector plan and replicability requirements. Implementation of the interventions began in October, 2012.

Participants in SDPP Consultative Design Workshop in October 2011



Students Studying in the Computer Labs Installed by SDPP



Early Warning System (to reduce student absenteeism and support at-risk students in school)

- Use existing school level data on attendance, performance, behavior etc. to identify students at-risk of dropping out of school
- Enhance the capacity of schools to address the needs of at-risk students
- Strengthen the partnership between school personnel and the parents/guardians of at-risk students

Computer Labs (to increase relevancy of education to students and parents/guardians)

- Install low-cost computer labs in schools, using a "thin-client" model powered entirely by solar energy
- Provide computer literacy training to students to increase perceptions of the value of and interest in schooling

### *Impact Assessment*

Intervention impact on dropout will be assessed using randomized control trials. Outcome measures include in- and between-grade dropout, grade completion, promotion, attendance, and performance. Changes in student, teacher, and parental knowledge, attitudes and practices for dropout prevention will also be measured. Data will be collected and analyzed at baseline, mid-term, and end-line.

| Outcome Indicators |
|---|
| **School dropout**: Does the student complete the academic year and enroll in the next? |
| **Engagement in school**: Does the student attend school regularly? Is his/her academic performance satisfactory? |
| **Progression in school**: Does the student move forward in the education cycle by being promoted? |
| **Student, Teacher, and Parent attitudes**: Do the students, teachers, and parents have a positive attitude towards schooling and dropout prevention? Do parents and teachers provide supportive environment at home and in the classroom? |

A sample of 322 schools was selected (based on an anticipated dropout reduction of 7 percentage points). Only schools that have target grades, are not subject to high migration, are accessible, have a room to dedicate to a computer lab and agree to participate in SDPP were included in the sample.




Schools were randomly assigned to treatment and control groups: 215 schools are implementing the EWS intervention, 108 schools (of the 215) also received computer labs, and 107 schools received no interventions and serve as the control group.


In Cambodia, SDPP is implemented by **Kampuchean Action for Primary Education (KAPE)**
**SDPP Office Phnom Penh:** #57, Street 302, Sangkat Boeung Keng Kang I, Khan Chamkarmon, Phnom Penh
**Tel:** (855)23 215-053; (855)23 215-058; P.O. Box: 2643 PP3

*For more information, contact Karen Tietjen, Creative Associates, at karent@creativedc.com or visit www.schooldropoutprevention.com*

USAID
ជំនួយពីពលរដ្ឋអាមេរិក

# កម្មវិធីសាកល្បងទប់ស្កាត់សិស្សបោះបង់ការសិក្សា



## ទិដ្ឋភាពទូទៅនៃកម្មវិធី

កម្មវិធីសាកល្បងទប់ស្កាត់សិស្សបោះបង់ការសិក្សា(SDPP) គឺជាកម្មវិធីពហុប្រទេសមានរយៈពេលបីឆ្នាំ ដែលត្រូវបានផ្តល់មូលនិធិដោយទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ (USAID) ក្នុងគោលបំណងដើម្បីកាត់បន្ថយសិស្សបោះបង់ការសិក្សានៅបឋមសិក្សា និងមធ្យមសិក្សា។ កម្មវិធីសាកល្បងទប់ស្កាត់សិស្សបោះបង់ការសិក្សា (SDPP) នឹង៖

- គ្រោងរៀបចំ និងសាកល្បងប្រសិទ្ធភាពនៃអន្តរាគមន៍ ដើម្បីទប់ស្កាត់សិស្សបោះបង់ការសិក្សានៅក្នុងប្រទេសចំនួនបួន រួមមាន ប្រទេសកម្ពុជា ឥណ្ឌា តាជីគីស្ថាន និងទីម័រលែស។
- បង្ហាញភស្តុតាងស្តីពីអន្តរាគមន៍ ដែលអាចត្រូវបានប្រើប្រាស់ដោយទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ (USAID) និងក្រសួងអប់រំ ដើម្បីកាត់បន្ថយអត្រាបោះបង់ការសិក្សា និងដោះស្រាយបញ្ហាឥរិយាបថនានា ដែលធ្វើឱ្យកុមារប្រឈមនឹងការបោះបង់ការសិក្សា។

## ប្រទេសកម្ពុជា

### និន្នាការនៃសិស្សបោះបង់ការសិក្សា

ការវិភាគទិន្នន័យពីប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំនៅកម្ពុជា (EMIS) បានបង្ហាញថា៖

- សិស្សបោះបង់ការសិក្សាច្រើនបំផុតនៅមធ្យមសិក្សាបឋមភូមិ ក្នុងចំណោមកុមារា និងកុមារី (២០%) បើធៀបនឹងបឋមសិក្សា (៩%) និងមធ្យមសិក្សាទុតិយភូមិ (១២%)។
- អត្រាបោះបង់ខ្ពស់បំផុតគឺនៅថ្នាក់ទី៧ ទី៨ និងទី៩។
- អត្រាបោះបង់កើនឡើងនៅត្រង់ចំណុចចូល/ចេញនៃភូមិសិក្សានីមួយៗ ពោលគឺថ្នាក់ទី៧ (២០%) ថ្នាក់ទី៩ (២១%) និងថ្នាក់ទី១២ (១៥%)។

*អត្រាបោះបង់តាមថ្នាក់៖ ឆ្នាំ២០០៩/១០*




### បរិបទនៃការបោះបង់ការសិក្សា

ការវិភាគតាមស្ថានភាពត្រូវបានធ្វើឡើងនៅក្នុងខេត្តបីដែលមានអត្រាបោះបង់ខ្ពស់ ដើម្បីកំណត់កត្តា និងស្ថានភាពនានាទាក់ទងនឹងសិស្សបោះបង់ការសិក្សា កំណត់ពីស្ថានភាពសិស្សប្រឈមនឹងការបោះបង់ និងផ្តល់ព័ត៌មានអំពីការគ្រោងរៀបចំ និងការជ្រើសរើសអន្តរាគម៍។ ហេតុផលចម្បងរបស់សិស្សបោះបង់ការសិក្សានៅថ្នាក់ទី៧ ទី៨ និងទី៩ នៅក្នុងខេត្តគោលដៅ ដែលត្រូវបានលើកឡើងដោយសិស្សប្រឈមនឹងការបោះបង់ សិស្សបោះបង់ការសិក្សា និងមាតាបិតា/អាណាព្យាបាលសិស្ស គឺបណ្តាលមកពីសេដ្ឋកិច្ច និងការសិក្សា។

<u>ហេតុផលសេដ្ឋកិច្ច</u>គឺជាមូលហេតុមួយក្នុងចំណោមមូលហេតុចម្បងទាំងបីដែលបានលើកឡើង៖

- សិស្សប្រឈមនឹងការបោះបង់ សិស្សបោះបង់ការសិក្សា និងមាតាបិតា/អាណាព្យាបាលរបស់សិស្សបោះបង់ការសិក្សា ជិតបីភាគបួនបានលើកឡើងថា ពួកគេត្រូវរកប្រាក់ចំណូលបន្ថែម តាមរយៈការងារប្រចាំថ្ងៃក្នុងផ្ទះ ឬការងារផ្សេងៗក្នុងគ្រួសារ ហើយប្រហែលជាពាក់កណ្តាលនៃអ្នកទាំងនេះបានលើកឡើងថាពួកគេត្រូវធ្វើការដើម្បីរកប្រាក់។
- សិស្សប្រឈមនឹងការបោះបង់ និងមាតាបិតា/អាណាព្យាបាលសិស្សប្រឈមនឹងការបោះបង់៥០% និងសិស្សបោះបង់ការសិក្សា និងមាតាបិតា/អាណាព្យាបាលសិស្សបោះបង់ការសិក្សា៣៣% បានលើកឡើងពីការចំណាយទៅលើសាលារៀន។

សិស្សក៏អាចបោះបង់ការសិក្សា ដោយសារតែ<u>ហេតុផលនៃការសិក្សាដែរ</u>៖

- សិស្សបោះបង់ការសិក្សាប្រហែលមួយភាគបី និងសិស្សប្រឈមនឹងការបោះបង់មួយភាគប្រាំបាននិយាយថា ពួកគេរៀនមិនទាន់គេ។
- សិស្សប្រឈមនឹងការបោះបង់ និងសិស្សបោះបង់ការសិក្សាប្រហែល២០%បានលើកឡើងថាលទ្ធផលសិក្សារបស់ពួកគេខ្សោយ។
- អវត្តមានច្រើនគឺជាកត្តាចម្បងមួយដែលនាំឱ្យសិស្សបោះបង់ការសិក្សា។ សិស្សប្រឈមនឹងការបោះបង់ជាង៥០% និងសិស្សបោះបង់ការសិក្សាមួយភាគបីខានមករៀនលើស១៥ថ្ងៃជាប់គ្នា ក្នុងនោះ៨០-៩០% ខានមករៀនដល់ទៅបួនថ្ងៃក្នុងមួយខែ។ មាតាបិតា/អាណាព្យាបាលសិស្សប្រឈមនឹងការបោះបង់៦៦% បានរាយការណ៍ថាពួកគាត់ឱ្យកូននៅផ្ទះ នៅពេលដែលកូនមិនមានជំងឺ ចំណែកឯមាតាបិតា/ អាណាព្យាបាលសិស្ស៥៦% បានរាយការណ៍ថា ពួកគាត់មិនបានដឹងថាកូនរបស់ពួកគាត់ទៅរៀនឬយ៉ាងណានោះទេ។
- ឥរិយាបថអវិជ្ជមាន៖ កុមារជាអ្នកឆ្លើយសំណួរប្រហែល១៦% និយាយថា ពួកគេមិនគោរពវិន័យសាលា។
- មាតាបិតា/អាណាព្យាបាលធៀបនឹងកូនរបស់ពួកគាត់ពីរដងនិយាយថា កូនរបស់ពួកគាត់មិនចូលចិត្តសាលារៀន។

កត្តាផ្សេងៗទៀត (អ្នកឆ្លើយសំណួរ១០%) ដែលបានលើកឡើងអំពីសិស្សបោះបង់ការសិក្សារួមមាន៖ ជំងឺ និងចម្ងាយផ្លូវពីផ្ទះទៅសាលារៀន។ កត្តាផ្សេងទៀតដែលមិនត្រូវបានលើកឡើងជាញឹកញាប់ មានជាអាទិ៍ គុណភាពសាលារៀនអន់ ហួសអាយុចូលរៀន គ្មានការលើកទឹកចិត្តពីគ្រូបង្រៀន រៀបអាពាហ៍ពិពាហ៍ និងកង្វះបង្គន់អនាម័យ។

*ហេតុផលចម្បងនៃការបោះបង់ការសិក្សាដែលសិស្សបោះបង់ការសិក្សានិងមាតាបិតា/អាណាព្យាបាលបានលើកឡើង*




*ហេតុផលចម្បងនៃការបោះបង់ការសិក្សាដែល បុគ្គលិកសាលារៀន មន្ត្រីអប់រំស្រុក ប្រធានសហគមន៍បានលើកឡើង*




## អន្តរាគមន៍

ក្នុងកិច្ចព្រមព្រៀងជាមួយក្រសួងអប់រំ យុវជន និងកីឡា កម្មវិធីសាកល្បងទប់ស្កាត់សិស្សបោះបង់ការសិក្សា (SDPP) នឹងកំណត់ជ្រើសរើសយកថ្នាក់ទី៧ ទី៨ និងទី៩ នៅក្នុងខេត្តចំនួន៦ មានជាអាទិ៍ ខេត្តបន្ទាយមានជ័យ បាត់ដំបង កំពង់ស្ពឺ ព្រៃវែង ពោធិ៍សាត់ និងស្វាយរៀង។ អ្នកពាក់ព័ន្ធផ្នែកអប់រំសំខាន់ៗបានចូលរួមក្នុងសិក្ខាសាលារៀបចំគម្រោង ដើម្បីអភិវឌ្ឍន៍គំនិត និងវិធីសាស្ត្រកាត់បន្ថយសិស្សបោះបង់ការសិក្សា តាមរយៈដំណើរការពិគ្រោះយោបល់។ អន្តរាគមន៍ជាអាទិភាពមានពីរគឺ ប្រព័ន្ធរំលឹកជាមុន និងបន្ទប់រៀនកុំព្យូទ័រ ត្រូវបានបង្កើតឡើងស្របតាមផែនការយុទ្ធសាស្ត្ររបស់ក្រសួងអប់រំ យុវជន និងកីឡា និងភាពដែលអាចយកទៅអនុវត្តបាន។ ការអនុវត្តនេះបានចាប់ផ្តើមក្នុងខែតុលា ឆ្នាំ២០១២។

*អ្នកចូលរួមក្នុងសិក្ខាសាលាពិគ្រោះយោបល់កម្មវិធី SDPP ក្នុងខែតុលា ឆ្នាំ២០១១*



*សិស្សកំពុងរៀនកុំព្យូទ័រក្នុងបន្ទប់រៀនកុំព្យូទ័រកម្មវិធី SDPP*



<u>ប្រព័ន្ធរំលឹកជាមុន</u> (ដើម្បីកាត់បន្ថយអវត្តមាន និងលើកទឹកចិត្តឱ្យសិស្សប្រឈមនឹងការបោះបង់នៅរៀនបន្ត)

- ប្រើប្រាស់ទិន្នន័យសាលារៀនដែលមានស្រាប់ដូចជា វត្តមាន លទ្ធផលសិក្សា និងឥរិយាបថ។ល។ ដើម្បីកំណត់សិស្សប្រឈមនឹងការបោះបង់ការសិក្សា។
- បង្កើនសមត្ថភាពបុគ្គលិកសាលារៀនដើម្បីដោះស្រាយតម្រូវការរបស់សិស្សប្រឈមនឹងការបោះបង់។
- ពង្រឹងភាពជាដៃគូរវាងបុគ្គលិកសាលារៀន និងមាតាបិតា/អាណាព្យាបាលសិស្សប្រឈមនឹងការបោះបង់។

<u>បន្ទប់រៀនកុំព្យូទ័រ</u> (ធ្វើឱ្យសិស្ស និងមាតាបិតា/អាណាព្យាបាលសិស្សកាន់តែយល់អំពីការអប់រំ)

- បំពាក់បន្ទប់រៀនកុំព្យូទ័រម៉ូឌែល “thin-client” ដែលមានតម្លៃថោក ប្រើថាមពលពន្លឺព្រះអាទិត្យនៅក្នុងសាលារៀន។
- ផ្តល់ការបណ្តុះបណ្តាលជំនាញកុំព្យូទ័រដល់សិស្ស ដើម្បីបង្កើនការយល់ដឹងអំពីតម្លៃ និងអត្ថប្រយោជន៍នៃការនៅរៀនបន្ត។

## ការវាយតម្លៃផលប៉ះពាល់

ផលប៉ះពាល់នៃអន្តរាគមន៍ទៅលើសិស្សបោះបង់ការសិក្សា នឹងត្រូវបានវាយតម្លៃដោយប្រៀបធៀបសាលាទទួលបានអន្តរាគមន៍ និងសាលាមិនទទួលបានអន្តរាគមន៍។ ការវាស់វែងលទ្ធផលនឹងធ្វើលើការបោះបង់ការសិក្សាតាមកម្រិតថ្នាក់ និងពីកម្រិតថ្នាក់មួយទៅកម្រិតថ្នាក់មួយ ការបញ្ចប់ការសិក្សាតាមកម្រិតថ្នាក់ ការឡើងថ្នាក់ វត្តមាន និងលទ្ធផលសិក្សា។ ការផ្លាស់ប្តូរចំណេះដឹង ឥរិយាបថ និងការអនុវត្តរបស់សិស្ស គ្រូបង្រៀន និងអាណាព្យាបាលក្នុងការទប់ស្កាត់សិស្សបោះបង់ការសិក្សា ក៏នឹងត្រូវវាស់វែងផងដែរ។ ទិន្នន័យទាំងនេះនឹងត្រូវបានប្រមូល និងវិភាគនៅពាក់កណ្តាលអាណត្តិនៃគម្រោង និងនៅពេលបញ្ចប់គម្រោង។

| សូចនាករលទ្ធផល |
|---|
| **សិស្សបោះបង់ការសិក្សា៖** តើសិស្សដែលរៀនចប់ឆ្នាំសិក្សានេះ នឹងចុះឈ្មោះចូលរៀននៅឆ្នាំសិក្សាបន្ទាប់ដែរឬទេ? |
| **ការមករៀន៖** តើសិស្សនេះមករៀនទៀងទាត់ដែរឬទេ? តើលទ្ធផលសិក្សារបស់សិស្សនេះបានគាប់ប្រសើរដែរឬទេ? |
| **ការរៀនបានរីកចម្រើន៖** តើសិស្សនេះរៀនបានឡើងថ្នាក់នៅក្នុងភូមិសិក្សាដែរឬទេ។ |
| **ឥរិយាបថសិស្ស គ្រូបង្រៀន និងមាតាបិតា៖** តើសិស្ស គ្រូបង្រៀន និងមាតាបិតាសិស្សមានឥរិយាបថវិជ្ជមានចំពោះការរៀនសូត្រ និងការទប់ស្កាត់សិស្សបោះបង់ការសិក្សាដែរឬទេ? តើមាតាបិតាសិស្ស និងគ្រូបង្រៀនផ្តល់ការគាំទ្រ និងលើកទឹកចិត្តនៅផ្ទះ និងនៅថ្នាក់រៀនដែរឬទេ? |

សំណាកសាលារៀនចំនួន៣២២ ត្រូវបានជ្រើសរើស (ផ្អែកលើការកាត់បន្ថយសិស្សបោះបង់ដែលរំពឹងទុក៧%)។ មានតែសាលារៀនដែលមានថ្នាក់គោលដៅ ដែលមិនមានចំណាកស្រុកខ្ពស់ ដែលមានផ្លូវងាយស្រួលអាចចូលទៅដល់ ដែលមានបន្ទប់សម្រាប់ដំឡើងបន្ទប់រៀនកុំព្យូទ័រ និងបានយល់ព្រមចូលរួមជាមួយកម្មវិធីសាកល្បងទប់ស្កាត់សិស្សបោះបង់ការសិក្សា (SDPP) ប៉ុណ្ណោះទើបត្រូវបានដាក់បញ្ចូលទៅក្នុងសំណាកនេះ។




សាលារៀនទាំងនេះត្រូវបានជ្រើសរើសព្រាវៗជាសាលាទទួលបានអន្តរាគមន៍ និងសាលាមិនទទួលបានអន្តរាគមន៍ ពោលគឺ សាលារៀនចំនួន២១៥ កំពុងអនុវត្តអន្តរាគមន៍ប្រព័ន្ធរំលឹកជាមុន សាលារៀនចំនួន១០៨ (ក្នុងចំណោមសាលារៀនចំនួន២១៥) ទទួលបានបន្ទប់រៀនកុំព្យូទ័រ និងសាលារៀនចំនួន១០៧មិនទទួលបានអន្តរាគមន៍ណាមួយឡើយ ហើយទុកជាសាលារៀនសម្រាប់ប្រៀបធៀប។

ក្នុងប្រទេសកម្ពុជា កម្មវិធី SDPP ត្រូវបានអនុវត្តដោយ **អង្គការសកម្មភាពសំរាប់បឋមសិក្សានៅកម្ពុជា** (ខេប/KAPE)
**ការិយាល័យភ្នំពេញ៖** ផ្ទះលេខ ៥៧ ផ្លូវលេខ ៣០២ សង្កាត់បឹងកេងកង ១ ខណ្ឌចំការមន រាជធានីភ្នំពេញ
**ទូរស័ព្ទ** ៖ (៨៥៥) ២៣ ២១៥ ០៥៣/២១៥ ០៥៨ ; **ប្រអប់សំបុត្រ** ៖ ២៦៤៣ ភ្នំពេញ ៣
សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងលោកស្រី Karen Tietjen, អង្គការអន្តរជាតិ គ្រីអេធីវអាសូស៊ីអេត (Creative Associate)
តាមរយៈអ៊ីម៉ែល៖ karent@creativedc.com ឬចូលទៅកាន់គេហទំព័រ www.schooldropoutprevention.com